# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** ជាតិ សាសនា ព្រះមហាក្សត្រ

លេខ:..១៩....សសរ

## សេចក្តីសំរេច

### ស្តីពី

### ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីធ្វើការសិក្សាលើធនធានខ្សាច់សំរាប់នាំចេញ ទៅកាន់ប្រទេសសិង្ហបុរី

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

### សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការអន្តរក្រសួងមួយដើម្បីធ្វើការសិក្សាលើធនធានខ្សាច់សំរាប់នាំចេញទៅកាន់ប្រទេសសិង្ហបុរីដែលមានសមាសភាព :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **សយ សុខា** | អគ្គលេខាធិការក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ប្រធាន |
| ២-ឯកឧត្តម | **ម៉ៅ ថូរ៉ា** | អគ្គនាយកបច្ចេកទេស នៃក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣-លោក | **ម៉ី លីហួត** | អគ្គនាយករងកិច្ចការរដ្ឋបាលនៃក្រសួងធនធានទឹក និង ឧតុនិយម | អនុប្រធាន |
| ៤-លោក | **សុខ ឡេង** | ប្រធាននាយកដ្ឋានធនធានរ៉ែ នៃក្រសួងឧស្សាហកម្ម | អនុប្រធាន |
| ៥-លោក | **សៀង សុថាង** | ប្រធាននាយកដ្ឋានភូគព្ភសាស្ត្រ នៃក្រសួងឧស្សាហកម្ម | សមាជិក |

| | | | |
|---|---|---|---|
| ៧-លោក | ពន នរារិន | ប្រធាននាយកដ្ឋាន វាយតំលៃ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៨-លោក | គាំង លាងខំណេ | ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| ៩-លោក | នរ ជុប | ប្រធាននាយកដ្ឋានពិនិត្យអង្កេតវាយតំលៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន | សមាជិក |
| ១០-លោក | ទាំ គីមស៊ីមសុរិយា | ប្រធាននាយកដ្ឋានផែនការ នៃក្រសួងសាធារណៈការ និងដឹកជញ្ជូន | សមាជិក |
| ១១-លោក | អេង ចាំសាន | អនុប្រធាននាយកដ្ឋានផលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១២-លោក | ជា វណ្ណដេត | អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ១៣-លោក | ទៅ សុទ្ធាង | ប្រធានផ្នែកកសិកម្ម ឧស្សាហកម្ម និងអភិវឌ្ឍន៍ជនបទ កសសស. | លេខាធិការ |
| ១៤-លោក | ខាំន់ តិរុណា | មន្ត្រី កសសស. | លេខាធិការ |

**ប្រការ ២ :** គណៈកម្មការនេះមានភារកិច្ច :

-ពិនិត្យជ្រើសរើសទីតាំងសំរាប់ធ្វើការដ្ឋានយកខ្សាច់ និងប្រមូលពត៌មានទាក់ទងដល់អាជីវកម្ម

-កំណត់បរិមាណ និងគុណភាពខ្សាច់ដែលផលិតបានសំរាប់ការផ្គត់ផ្គង់ក្នុងស្រុក និងនាំចេញ

-ស្រាវជ្រាវតំលៃលក់ក្នុងស្រុក និងតំលៃនាំចេញខ្សាច់តាមយថាប្រភេទ

-ពិនិត្យ និងការពារផលប៉ះពាល់បរិស្ថាន ដែលទាក់ទងដល់ការធ្វើអាជីវកម្មខ្សាច់

-ពិនិត្យ ពិភាក្សាលើបញ្ហាបច្ចេកទេស បែបបទ និងនិតិវិធីផ្សេងៗដែលទាក់ទងដល់ការធ្វើអាជីវកម្ម និងការនាំចេញខ្សាច់

-រាយការណ៍អំពីលទ្ធផលចរចាជាមួយគណៈប្រតិភូសិង្ហបុរីអំពីការធ្វើអាជីវកម្មលើការនាំចេញខ្សាច់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

**ប្រការ ៣ :** អនុប្រធាន សមាជិកគណៈកម្មការត្រូវចូលរួមការប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

**ប្រការ ៤ :** គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រីជាផ្លូវការ ។

**ប្រការ ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណៈការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ អោយ មានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចប្រការ ៥
-ឯកសារ- កាលប្បវត្តិ